

# មនុស្សនិងដី

ពាំង ជូឈាន

៦១១.
៩

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

៦១១.៩

# មនុស្សនិងដី

អាំង ជូលាន

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ពិព័រណ៍

បើកថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០

រីយំ
reyum
GALLERY

ផ្ទះលេខ ៤៧ ផ្លូវលេខ ១៧៨ (ក្បែរសាកលវិទ្យាល័យ:មន្ទីរជាតិ)
ប្រអប់សំបុត្រលេខ ២៤៣៨, ភ្នំពេញ
ទូរស័ព្ទលេខ (៨៥៥) ០២៣ ២១៧ ១៤៩
ឬ ០១២ ៨០៦ ១៥០ ឬ ០១២ ៨៣៦ ៤៧១
E-mail : reyum@camnet.com.kh

www.budinst.gov.kh www.elibraryofcambodia.org

## អារម្ភកថា

*រៃយំ* ជាទីកន្លែងមួយសម្រាប់ផ្តល់ឱកាសឱ្យអ្នកស្រាវជ្រាវ, សិល្បករ, អ្នកភ្លេង, អ្នកនិពន្ធ, អ្នកថតកុន។ល។ បង្ហាញស្នាដៃ និងផ្លាស់ប្តូរគំនិតគ្នា។ ក្នុងគោលគំនិតនេះរៃយំក៏បានអញ្ជើញលោក អាំង ជូលាន មកធ្វើពិព័រណ៍បង្ហាញខ្លឹមសារមួយផ្នែកនៃការស្រាវជ្រាវដ៏យូរអង្វែងរបស់គាត់។ យើងខ្ញុំមានសង្ឃឹមថានេះជាជំហានតូចនៃចលនាមួយដែលនឹងជំរុញឱ្យខ្មែរទាំងអស់មានចិត្តចង់រក្សា, បង្កើត និងពង្រីកគំនិតខ្លួន។ ពីព្រោះនេះជាកត្តាសំខាន់សម្រាប់បច្ចុប្បន្ន និងការកសាងអនាគតរបស់សង្គម។

*រៃយំ* រស់ដោយសារការគាំទ្រ និងជួយជ្រោមជ្រែងរបស់មនុស្សមួយចំនួននិងបានទទួលថវិកាខ្លះពីមូលនិធិកាស៊ូមីស៊ូ *(The Kasumisou Foundation)*។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះគេទាំងអស់។

ក្នុងការរៀបចំកិច្ចការនេះ, ប្រសិនបើមានខុសឆ្គង ឬក៏ខ្វះខាតអ្វីសូមមេត្តាអភ័យទោស។

ប្រធាន *រៃយំ*

លី តារារុធ និង អាំងគ្រីដ មុិអាន់

www.budinst.gov.kh www.elibraryofcambodia.org

# មនុស្សនិងដី

អាំង ជូលាន

ប្រព័ន្ធជំនឿនៃជនជាតិខ្មែរ មិនអាចសង្ខេបមកថាជាសាសនាអ្វីមួយសុទ្ធសាតបានទេ ថ្វីត្បិតតែសព្វថ្ងៃព្រះពុទ្ធសាសនាថេរវាទគ្របដណ្តប់ទឹកដីខ្មែរទាំងមូលក៏ដោយ។ ក្នុងប្រវត្តិរបស់ខ្លួន ខ្មែរបានទទួលឥទ្ធិពលពីក្រៅសន្ធឹកសន្ធាប់រាប់មិនអស់។ បើពោលពីបុរាណកាលវិញ គឺឥទ្ធិពលឥណ្ឌាបានហូរចូលមក ហើយជ្រួតជ្រាបក្នុងសង្គមខ្មែរម្តងបន្តិចៗ។ ការហូរចូលមកនោះសោតក៏មិនមែនកើតឡើងមួយឆ្នាំ មួយទសវត្ស ឬមួយសតវត្សដែរ គឺច្រើនសតវត្ស។ ដូច្នោះការជ្រួតជ្រាបនោះពុំមែនសើៗទេ ប៉ុន្តែចាក់ឫសជ្រៅមាំក្នុងគំនិតនិងជំនឿខ្មែរ។

តើឥទ្ធិពលឥណ្ឌានោះជះមកលើសង្គមមួយ ដែលពុំធ្លាប់មានជំនឿអ្វី ឬ មួយយ៉ាងណា?

ជនជាតិខ្មែរធ្លាប់មានប្រព័ន្ធជំនឿម្យ៉ាងប្រហាក់ប្រហែលគ្នានឹងជំនឿនៃជនជាតិដទៃទៀតច្រើននៅអាស៊ីអាគ្នេយ៍ដែរ។ សព្វថ្ងៃគេសន្មតឈ្មោះឲ្យថា 'ជីវចល'។ ជីវចលនេះ នៅតែរស់រវើកជាធម្មតារហូតដល់សព្វថ្ងៃ។ ដូច្នោះមានន័យថាព្រហ្មញ្ញសាសនា បន្ទាប់មកថេរវាទ ពុំបានធ្វើឲ្យជីវចលរលាយបាត់ឡើយ។ ម្យ៉ាងទៀត បើពោលថាព្រហ្មញ្ញសាសនា និងជីវចលមានដំណើរការស្របគ្នា តែមិនពាក់ព័ន្ធគ្នាក៏នៅតែខុស។ ការពិត គឺមិនមែនជាចរន្តពីរដែលនៅដោយឡែកពីគ្នាឡើយ ប៉ុន្តែជាចរន្តដែលចុះសម្រុងគ្នា វេញបានជាធ្លុងមួយ ហើយបង្កើតបានជាប្រព័ន្ធតែមួយ។ សព្វថ្ងៃដែលខ្មែរប្រកាន់យកព្រះពុទ្ធសាសនា ក៏មរតកខាងលើនេះ មកបញ្ចូលខ្លួនជាមួយ វេញគ្នាជាធ្លុងតែមួយទៀត។ បើពុំដូច្នោះ ហេតុអ្វីបានជាយើងតែងឃើញមានខ្ទមអ្នកតានៅក្នុងបរិវេណវត្ត ?

ចំណុចដែលគួរចាប់អារម្មណ៍ព្រមទាំងគួរយកមកពិចារណា គឺការចាក់ស្រេះចូលគ្នានេះ កើតឡើងរបៀបដូចម្តេច. មានអ្វីមួយជាស្ពានចម្លងភ្ជាប់គ្នាទៅវិញទៅមកបាន ហើយអ្វីទៅជាមូលដ្ឋានគំនិតដើម ព្រមទាំងជាយន្តកម្ម។ នៅទីនេះ ខ្ញុំចង់យកឧទាហរណ៍ 'អ្នកតា' មកពិនិត្យ។ ឯពិនិត្យនោះសោត ក៏នឹងពុំវែកញែកវែងឆ្ងាយអំពីពិធីផ្សេងៗ គុចក្តីជំក្តី ដែលគេប្រារព្ធចំពោះអ្នកតាដែរ គឺគ្រាន់តែយកវត្ថុស្នងអ្នកតាមកពិចារណាតែប៉ុណ្ណោះ។ ហេតុអ្វីបានជាខ្ញុំយកឧទាហរណ៍អ្នកតា? មកពីក្នុងជំនឿជីវចលខ្មែរ អ្នកតាជាអមនុស្សដែលសំខាន់បង្អស់.

www.budinst.gov.kh www.elibraryofcambodia.org

មានរោងឬទីអ្វីមួយជាសំគាល់, មានវត្ថុស្នង, មិនតែប៉ុណ្ណោះ អាចមានដល់ទៅ 'រូប' ជាមនុស្សស្នងសម្រាប់បញ្ជាន់ឆ្លងឆ្លើយនឹងអ្នកស្រុកទៀតផង។

អ្នកតានេះពុំដឹងជានៅសម័យបុរាណ ឬពីបុរេប្រវត្តិមក គេហៅថាអ្វីទេ ប៉ុន្តែចំពោះជំនឿនោះមានពីយូរយាមក ដែលស្មារតីមនុស្សពុំអាចចងចាំបាន។ អ្នកតាមិនមែនជាខ្មោច ឬអមនុស្សកំប៉ិកកំប៉ុកទេ គឺជាបាតុភូតដែលពាក់ព័ន្ធនឹងសហគមន៍មួយក្រុម ឧទាហរណ៍ទាក់ទងនឹងប្រជាជនមួយភូមិតែម្តង។ នេះបានសេចក្តីថា អ្នកតាជាទីប្រជុំ ឬជាមេបណ្តាញនៃភូមិករទាំងមូល ប្រៀបបីដូចជា 'មេភ្លើង' ដែលជាទីប្រជុំខ្សែអគ្គីសនីខាត់ខ្វែង នៃសង្កាត់មួយ ឬក្រុមគេហដ្ឋានមួយចំនួន។ បើនិយាយពីចរន្តអគ្គីសនី គេហដ្ឋានមួយចំនួននោះភ្ជាប់វាសនាគ្នាតាមរយៈមេបណ្តាញនោះឯង។

តើវាសនានៃសហគមន៍អ្នកស្រុកមួយ -និយាយកាត់ខ្លីដើម្បីងាយស្រួលថាភូមិមួយ- ពឹងផ្អែកទៅលើអ្វី? ចំពោះអ្នកស្រែចំការដែលរស់ក្នុងរបប 'មូសុង' នោះ គឺពឹងពាក់លើភ្លៀង។ បញ្ហាភ្លៀងនៅកម្ពុជា ឬប្រទេសជិតខាង គឺភ្លៀងច្រើនហួស ក្នុងរយៈពេលខ្លីហួស។ ដូច្នោះហើយកង្វល់នៃអ្នកស្រុកគឺធ្វើម្តេចឱ្យមានភ្លៀងគ្រប់គ្រាន់ ក្នុងរយៈពេលគ្រប់គ្រាន់។ កាលបើបានដូចបំណងនេះមែន ភោគផលដែលទាញយកមកពីដី នឹងបានបរិបុណ៌ រីឯសត្វពាហនៈក៏មានស៊ីគ្រប់គ្រាន់ឥតមានជម្ងឺដំកាត់អ្វី។ ក្នុងទស្សនៈជំនឿដើម្បីទាញភោគផលតាមរយៈទឹកភ្លៀងនេះមនុស្សងាកទៅរកល្បិច ឬកិច្ចអ្វីមួយដែលត្រាប់តាមអំពើបន្តពូជរបស់ខ្លួនឯង។ ភោគផលដែលចេញមកពីដី មិនខុសអ្វីពីកូនដែលចាប់កំណើតហើយចេញពីផ្ទៃម្តាយមកដែរ។ ដូច្នោះគ្មានអ្វីប្លែកឡើយ ដែលយើងឃើញអ្នកតាខ្លះមានលំនាំរាងតាមអង្គជាតិមនុស្សប្រុស ឬមួយក៏ជាលិង្គថ្មដែលធ្លាក់ពីសម័យបុរាណមកតែម្តង។ ជួនកាលគេធ្វើរហូតទៅដល់ខ្នាសនៃភេទទាំងពីរ ពើបប្រសព្វគ្នានៅជិតថ្មអ្នកតាទៀតផង។

ចុះហេតុអ្វីបានជាអ្នកតាច្រើនតែជាថ្មមួយដុំ ? តាមពិតដុំថ្មនោះស្នងឱ្យភូមិករទាំងមូល ពោលគឺលំនៅដ្ឋាន, ស្រែចំការ, បឹងត្រពាំង, និងព្រៃជិតៗនោះ ដែលមនុស្សទៅរកឧស់រាល់ថ្ងៃជាដើម។ ក្នុងន័យនេះ ដុំថ្មដែលសន្មតហៅថា 'អ្នកតា' ស្នងឱ្យ –ឬបើនិយាយឱ្យច្បាស់ជាងនេះទៀតគឺ 'ជា'– ដីភូមិករទាំងមូលនោះតែម្តង។ ដើម្បីប្រៀបធៀបឱ្យងាយ គួរលើកយកករណីកែវពង្រីក មកធ្វើជាឧទាហរណ៍។ បើយើងកាន់កែវពង្រីកមួយក្រោមពន្លឺថ្ងៃ ពេលថ្ងៃត្រង់ហើយ

www.budinst.gov.kh www.elibraryofcambodia.org

វេកមុមឲ្យត្រូវ យើងនឹងបានចំណុចពន្លឺថ្ងៃមួយយ៉ាងតូចដែលចេញមកក្រោម។ ចំណុចតូចនេះ ចាំងភ្លឺព្រមទាំងក្ដៅចម្លែក រហូតអាចដល់ទៅដុតក្រដាស ឬស្លឹកឈើងាប់ចេះឆេះផង។ តាមពិត ចំណុចដ៏តូចនេះ ជាទីប្រជុំផ្ដុំនៃកាំរស្មីយ៉ាងច្រើនឥតគណនា ហើយដែលវាយគ្នាលាតសន្ធឹង តាមមុំមួយធំ វិស័យដូចវាំងផ្ចិតដែលគេបើក។ ដូច្នោះហើយ ចំណុចតូចពុំមែនគ្រាន់តែស្នងឲ្យកាំរស្មីចំនួនដ៏លើសលុបនោះទេ ៖ ចំណុចតូចគឺ 'ជា' កាំរស្មីទាំងអស់នោះឯង។ រីឯដុំថ្មអ្នកតាក៏ពុំខុសអ្វីពីនោះដែរ។ ដុំថ្មមួយដុំនោះ គឺជាដីភូមិករទាំងមូលនោះតែម្ដង។ ដូច្នោះហើយបានជាបើយើងធ្វើពិធីត្រឹមត្រូវលើដុំថ្មនោះ (មានជាអាទិ៍ក្នុងឱកាសឡើងអ្នកតា ប្រចាំឆ្នាំជាដើម) ភ្លៀងនឹងស្រោចស្រប់មកលើស្រែចំការ ច្បារដំណាំជុំវិញផ្ទះ ត្រជាក់ត្រជុំដល់មនុស្ស និងគោក្របី។ បើយើងធ្វើពិធីដដែលនៅលើអ្វីមួយដែលមិនមែនជាទីប្រជុំនៃសសៃថាមពលភូមិស្រុកទាំងមូល ក៏ឥតប្រយោជន៍ ព្រោះវត្ថុអ្វីមួយនោះពុំមែន 'ជា' ភូមិនោះ។ ប្រៀបបីដូចជាយើងថ្លោះអ្វីមួយក្នុងសរីរាង្គ បើចាប់ ឬច្រិះខុសសសៃក៏ពុំអាចធ្វើឲ្យការចុកចាប់ស្បើយវិញបាន។

## សន្និដ្ឋានទីមួយ ៖ អ្នកតា ⁼ ដី

ប៉ុន្តែវត្ថុស្នងដែលហៅថាអ្នកតានោះ ជួនកាលពុំមែនជាថ្មសុទ្ធសាធ (ឬដំបូកកណ្ដៀរ ឬចេតិយបុរាណបាក់បែកខូចរូបរាងដែលមានន័យដូចថ្ម) ប៉ុណ្ណោះទេ។ ជួនកាលយើងឃើញដុំថ្មនេះមានក្រណាត់មកហ៊ុំជៀង បីដូចគេពាក់អាវផាហ៊ុំ ឬកន្សែងអ្វីមួយ។ ដូច្នោះហើយ ថ្វីត្បិតតែដុំថ្ម ឥតមានរូបរាងមនុស្ស ក៏មានអ្វីមួយជាលក្ខណៈមនុស្សបន្តិចដែរ។

ជួនកាលទៀត គេធ្វើរូបរាងមនុស្សពេញលេញតែម្ដង ហើយសន្មតហៅថាអ្នកតា។ បើដូច្នោះហើយ គ្មានអ្វីនាំឲ្យសង្ស័យទៀតទេ គឺអ្នកតាជាមនុស្សដែរ (ឬពោលឲ្យចំថា ជាអមនុស្សដែលមានរូបរាងដូចមនុស្ស)។

## សន្និដ្ឋានទីពីរ ៖ អ្នកតា ⁼ មនុស្ស

ប៉ុន្តែរូបស្នងពុំមែនមានតែពីរយ៉ាងទេ។ ប្រភេទទីបី គួរឲ្យយើងចាប់អារម្មណ៍ជាទីបំផុត ព្រោះជាដីផង ជាមនុស្សផង បូកបញ្ចូល ឬលាយចូលគ្នា។ ជួនកាលគេឃើញថ្មមួយដុំដែលគ្មានរាងអ្វីមួយប្រាកដ ហើយដែលគេយកមុខមនុស្សធ្វើអំពីស៊ីម៉ង់ត៍ជាដើម ទៅបិតពីលើ។ បើពុំដូច្នោះ ក៏គង់មានសណ្ឋានជាមនុស្ស ដែលក្លាយចេញអំពីថ្ម ឬដំបូកអ្វីមួយដែរ។ ត្រង់នេះហើយដែលគេអាចយល់បានថា ខ្មែរសម័យបុរាណទទួលយកជំនឿលើលិង្គផង លើបដិមាដែលមានមុខមាត់ជា

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សផង ព្រមទាំងលើ 'មុខលិង្គ' (លិង្គដែលឆ្លាក់មុខមនុស្សភ្ជាប់ជាមួយ)។ ម្យ៉ាងទៀតត្រង់នេះហើយដែលគេអាចចាប់បាននូវទំហំន័យទាំងមូលនៃអ្នកតា ៖ អ្នកតាជាបុព្វបុរសនៃសហគមន៍ជនបទមួយ ទោះជាមានប្រវត្តិពិត ឬប្រវត្តិនោះប្រឌិតហើយគោរពជឿតៗគ្នាមកក៏ដោយ។ បុព្វបុរសនោះជាជនអង់អាចម្នាក់ដែលទៅរានព្រៃណាមួយកន្លែងមុនគេ, ដែលទប់ទល់នឹងខ្មោចព្រៃព្រមទាំងការចាញ់ទឹកដីបាន។ ជននោះបានធ្វើឱ្យព្រៃមួយដុំក្លាយទៅជាស្រុក, ធ្វើវិស័យមួយដែលគ្មានមនុស្ស ហើយដែលពោរពេញទៅដោយគ្រោះថ្នាក់ ឱ្យទៅជាភូមិករប្រកបដោយភោគផល។ ជនទីមួយនោះហើយ ដែលទាក់ទាញអ្នកដទៃទៀត ឱ្យមកពង្រីកសហគមន៍នោះកាន់តែធំឡើងៗ ឱ្យមានអារ្យធម៌, មានវត្តអារាម។ល។ ច្រើនជំនាន់ក្រោយមក កេរ្តិ៍ឈ្មោះនៃបុព្វបុរសនោះហាក់ដូចជាពុំអាចផ្តាច់បានឡើយពីដីដែលខ្លួនបាននាំអាទិ៍កាប់ឆ្ការ ព្រមទាំងនាំគេដទៃទាញយកភោគផល ត្បិតប្រវត្តិគាត់ –ពិត ឬប្រឌិត– សង្ខេបមកថា មនុស្សទៅធ្វើដីព្រៃឱ្យក្លាយជាស្រុក។

សន្និដ្ឋានបញ្ចប់ ៖ អ្នកតា = មនុស្ស + ដី

---

អាំង ជូលាន

កើតនៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ១៩៤៩ នៅកំពង់ឃ្លាំង ខេត្តសៀមរាប។

.បរិញ្ញាបត្របុរាណវិទ្យា (សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ ១៩៧៤)

.បណ្ឌិតខាងនរវិទ្យា (បារីស ១៩៨២)

សព្វថ្ងៃជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យបុរាណវិទ្យា និងកាន់កាប់ នាយកដ្ឋាន 'វប្បធម៌និងវិមណណីយដ្ឋាន នៃអាជ្ញាធរអប្សរា។

www.budinst.gov.kh www.elibraryofcambodia.org

ដី ៖ សាបព្រួស ពង្រៃ្ល និងបញ្ចូលភោគផល

www.budinst.gov.kh www.elibraryofcambodia.org



ថ្មមានលំនាំរាងជាអង្គជាតិ...

www.budinst.gov.kh www.elibraryofcambodia.org



ដែលគេយកខ្នាសទាំងពីរនេះ ឆ្លាក់លើវត្ថុជាតិ ទៅធ្វើជាតង្វាយ...

www.budinst.gov.kh www.elibraryofcambodia.org



...ដើម្បីបញ្ជាក់នៃពីអនុភាពនៃការសាបព្រួសបង្កើតភោគផល

www.budinst.gov.kh www.elibraryofcambodia.org



លិង្គ(-ងី) ធ្វើតាមលំនាំធម្មជាតិពិត។ បញ្ជាក់ពីអនុភាពនៃការសាបព្រួសពូជ

www.budinst.gov.kh www.elibraryofcambodia.org



យោនី(•ដី) ឬអនុភាពនៃការផ្ទុកនិងបញ្ចេញផលដែលបញ្ជាក់ន័យដោយចម្លាក់ "តាមលំនាំធម្មជាតិ"
នៅក្នុងចំពូយតម្រង់

www.budinst.gov.kh www.elibraryofcambodia.org



ដីដែលពេញលេញ គឺមានភេទទាំងពីររួមគ្នា...

www.budinst.gov.kh www.elibraryofcambodia.org




...សាបព្រួសផង ពភោគផលក្នុងផ្ទៃ និងបញ្ចេញភោគផលនោះផង

www.budinst.gov.kh www.elibraryofcambodia.org



បារាយទឹកថ្លា៖ ប្រភពដ៏សំខាន់មួយនៃការស្រោចស្រប់។ នៅទីនេះ គេរៀបថ្មធ្វើជាអណ្តូង-លិង្គ(លិង្គ ប្រហោង) មួយ...

www.budinst.gov.kh www.elibraryofcambodia.org



...មុជទៅក្នុងទឹក។ ទឹកនេះហើយដែលគេបញ្ចេញទៅស្រែចម្ការផ្សេងៗតាមផ្លូវព្រាំង

www.budinst.gov.kh www.elibraryofcambodia.org



នៅ ‘ក្បាលស្ពាន’ (តំបន់គូលែន) ក៏ដូច្នោះដែរ ទឹកហូរចុះមកក្រោមដល់វាលទំនាប ក្រោយពីបានឆ្លងកាត់តាមលិង្គ-យោនីជាច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ដីសុទ្ធ គ្មានទ្រង់ទ្រាយប្រាកដ

www.budinst.gov.kh www.elibraryofcambodia.org



ដុំថ្មដែលគ្មានរាងអ្វីប្រាកដ

www.budinst.gov.kh www.elibraryofcambodia.org



ដុំថ្មដែលមានទលំទាំទ្រង់ទ្រាយជាអង្គជាតិ និង...

www.budinst.gov.kh www.elibraryofcambodia.org



...លិង្គកាលជំនាន់ព្រហ្មញ្ញសាសនា

www.budinst.gov.kh www.elibraryofcambodia.org



ដំបូកកណ្ដៀរ • ដីដែលមានចលនារើក

www.budinst.gov.kh www.elibraryofcambodia.org



លិង្គកប់លាយឡំនឹងដំបូក

www.budinst.gov.kh www.elibraryofcambodia.org

...ចូរដកាត់តាមភាពជាមនុស្សខ្លះ...

www.budinst.gov.kh www.elibraryofcambodia.org



ដុំថ្មតាធាវៀស្ស ៖ ថ្មនេះពុំមានរូបជាមនុស្សទេ...

www.budinst.gov.kh www.elibraryofcambodia.org



...ប៉ុន្តែក្រណាត់ហ៊ុំធ្វើឲ្យយើងគិតថាមានលក្ខណៈមនុស្សខ្លះ។

www.budinst.gov.kh www.elibraryofcambodia.org



ដំបូកដែលគេភាទាឱ្យ

www.budinst.gov.kh www.elibraryofcambodia.org



ចេតិយ៍បុរាណទ្រុតទ្រោម ខូចរូបរាង...

www.budinst.gov.kh www.elibraryofcambodia.org



...ដែលគេស្លៀកពាក់ឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

...មកដល់បុញ្ញបុរស រូបរាងជាមនុស្សពេញលេញ...

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY



អ្នកតាមានរូបរាងជាមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org



...ដែលជាទិដ្ឋភាពបញ្ច្រាសអំពីថ្មធម្មជាតិ គ្មានទ្រង់ទ្រាយប្រាកដ

www.budinst.gov.kh www.elibraryofcambodia.org



គូប្ដីប្រពន្ធអ្នកតា ដែលជា...

www.budinst.gov.kh www.elibraryofcambodia.org



...ទិដ្ឋភាពបញ្រ្កាសអំពីគុលិង្គ-យោនី

www.budinst.gov.kh www.elibraryofcambodia.org

...ដោយអាចត្រឡប់ទៅរកភាពឥតរាងប្រាកដវិញបាន(?)

www.budinst.gov.kh www.elibraryofcambodia.org



បដិមាឈើចាស់រូបរាងដើមច្រើន រិចរិលជុំវិញ ហើយនៅសល់លំនាំរូបរាងបែបផែនអង្គជាតិ

www.budinst.gov.kh www.elibraryofcambodia.org



ចេតិយ៍ចាស់បាក់បែក ដែលគេមិនជួសជុលដោយចេតនា ហើយដែលមានទច័យជំនឿប្រហាក់ប្រហែលនឹង ថ្មឥតរូបរាង ឬដំបូកដែរ...

www.budinst.gov.kh www.elibraryofcambodia.org



...ប៉ុន្តែដែលគេគោរព រហូតដល់ផ្តួចកាលធ្វើជាជម្រកការពាររក្សាទៀតផង

www.budinst.gov.kh www.elibraryofcambodia.org



ព្រះពុទ្ធរូបប្រក់នាគនៅអង្គរវត្ត ដែលកណ្ដៀរពុន ហើយដែលអ្នកស្គាល់មួយក្ដាប់តូចគោរពបូជា

www.budinst.gov.kh www.elibraryofcambodia.org

ដីដែលមានរូបរាងមនុស្ស ឬ បុព្វបុរសនិងដីរលាយចូលគ្នា

www.budinst.gov.kh www.elibraryofcambodia.org



ដំបូកដែលគេឆ្លាក់

www.budinst.gov.kh www.elibraryofcambodia.org



ថ្មធម្មជាតិមួយដុំ ដែលគេបំពេញរូបរាងជាមនុស្សឱ្យ ដោយយកដីឥដ្ឋមកភ្ជាប់

www.budinst.gov.kh www.elibraryofcambodia.org



ថ្មមួយដុំ ឫសឈើ...

www.budinst.gov.kh www.elibraryofcambodia.org



...រួមគ្នាជាមួយព្រះកេស

www.budinst.gov.kh www.elibraryofcambodia.org




ថ្មធម្មជាតិ...

www.budinst.gov.kh www.elibraryofcambodia.org



...មានក្បាលស៊ីម៉ង់ដ៏បិតភ្ជាប់ជាមួយ

www.budinst.gov.kh www.elibraryofcambodia.org



ចម្លាក់រូបរាងមនុស្សរលាយចូលគ្នានឹងដំបូកដែលគ្មានលំនាំរាងប្រាកដ

www.budinst.gov.kh www.elibraryofcambodia.org



"មុខលិង្គ" ៖ គួរឲ្យប្រៀបធៀបនឹងដុំថ្មមានមុខមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org



មុខលិង្គស្លៀកស្បង់ ៖ ដីដែលឈានទៅរកភាពជាមនុស្សមួយកម្រិតទៀត

www.budinst.gov.kh www.elibraryofcambodia.org



គេតាំងរូបមនុស្សបន្ថែមនៅជិតមុខលិង្គ ហាក់បីដូចជាខ្លាចថាមិនទាន់គ្រប់គ្រាន់លក្ខណៈជាមនុស្ស

www.budinst.gov.kh www.elibraryofcambodia.org

សាសនាព្រាហ្មណ៍ប្រឈមមុខនឹងភូមិសាស្ត្រ ព្រមទាំងជំនឿនៅតំបន់ជាទី

www.budinst.gov.kh www.elibraryofcambodia.org



ភ្នំកៃលាស ស្ទង់ដោយភ្នំ 'ថ្មដុះ' នៃភូមិសាស្ត្រជាក់ស្តែង...

www.budinst.gov.kh www.elibraryofcambodia.org



...ជាល់នៅស្ថាននៃព្រះឥសូរ (ប្រាសាទថ្មដុះ)...

www.budinst.gov.kh www.elibraryofcambodia.org



...ដែលគេឃើញកំពុងរាំនៅលើថ្ម

www.budinst.gov.kh www.elibraryofcambodia.org



តាមធម្មតា ក្នុងនោះគួរតែមានបដិមាព្រះឥសូរ ជាពិសេសលិង្គ (ដែលស្នងឲ្យទេពនោះ)។ ប៉ុន្តែបែរជាឃើញ "ថ្មផុះ" ជាថ្មធម្មជាតិ គ្មានឆ្លាក់ឬរំលីងអ្វីទាំងអស់ (ឃើញតែបន្តិចទេនៅទីនេះ)...

www.budinst.gov.kh www.elibraryofcambodia.org



...ដែលមានទទឹងស្មើរប៉ុនទំហំក្នុងនៃប្រាសាទ (មើលពីក្រោយ) ហើយដែលសាងដោយផ្ចិតផ្ចង់ ប្រកប ដោយសិល្បៈខ្ពស់

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារពិគ្រោះ


Ang Chouléan

*Les êtres surnaturels dans la religion populaire khmère*, Cedoreck, Paris 1986.

Ang Chouléan

« Nouvelles recherches sur le culte des mégalithes et des grottes au Cambodge », *Journal Asiatique*, CCLXXXI, Paris 1993, p.183-210.

Ang Chouléan

« Le sol et l'ancêtre. L'amorphe et l'anthropomorphe », *Journal Asiatique*, CCLXXXIII, Paris 1995, p.213-238.

Bhattacharya, Kamaleswar

*Les religions brahmaniques dans l'ancien Cambodge d'après l'épigraphie et l'iconographie*, Ecole Française d'Extrême-Orient, Paris 1961.

Condominas, Georges

*Nous avons mangé la forêt de la Pierre-Génie Gôo*, Mercure de France, Paris, 1957.

Mus, Paul

« Cultes indiens et indigènes au Champa », *Bulletin de l'Ecole Française d'Extrême-Orient*, XXXIII, 1934, p.367-410.

Porée-Maspéro, Eveline

*Etudes sur les rites agraires des Cambodgiens*, Mouton & Co, Paris-La Haye, 3 tomes, 1952-1969.

Porée-Maspéro, Eveline

« Traditions orales de Pursat et de Kampot », *Artibus Asiae*, XXIV, 1961, p.394-398.

Souyris-Rolland, André

« Contribution à l'étude du culte des génies tutélaires ou Néak Ta chez les Cambodgiens du Sud », *Bulletin de la Société des Etudes Indochinoises*, XXVI, 1951, p.161-173.


www.budinst.gov.kh www.elibraryofcambodia.org

រេយ៉ំ
reyum
ឧបត្ថម្ភដោយមូលនិធិ កាស៊ុមិស៊ូ (The Kasumisou Foundation)
www.budinst.gov.kh - www.elibraryofcambodia.org